# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៥៩ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពី

## ការទទួលស្គាល់សាកលវិទ្យាល័យ ឡាយហ្វ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក. ចុះថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ០១ អនក្រ ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ១៩៩២ ស្តីពីការបង្កើត និងការគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សា និងសិក្សាឯកទេស
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០០២ ស្តីពីលក្ខណៈវិនិច្ឆ័យ នៃការបង្កើតសាកលវិទ្យាល័យ
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០០៧ ស្តីពីការបណ្តុះបណ្តាលក្នុងវិស័យសុខាភិបាល
- បានឃើញយោបល់របស់ក្រសួងអប់រំ យុវជន និងកីឡា តាមលិខិតលេខ ២១៥៩ អយក.ឧស ចុះថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០០៧

# ស ម្រេ ច

**មាត្រា ១ :** ទទួលស្គាល់ គ្រឹះស្ថានឧត្តមសិក្សាឯកជនមួយ ដែលមានឈ្មោះថា **សាកលវិទ្យាល័យ ឡាយហ្វ** ( **Life University** ) ហៅកាត់ជាភាសាខ្មែរ " **ស.ឡ** " និងហៅកាត់ជាភាសាអង់គ្លេស " **L.U** " ។ សាកលវិទ្យាល័យ ឡាយហ្វ មានទីតាំងស្ថិតនៅ ផ្លូវសេតេ ក្រុម ១០ មណ្ឌល ៣ សង្កាត់លេខ ០២ ខណ្ឌមិត្តភាព ក្រុងព្រះសីហនុ និងស្ថិតនៅក្រោមឱវាទក្រសួងអប់រំ យុវជន និងកីឡា។

**មាត្រា ២ :** សាកលវិទ្យាល័យ ឡាយហ្វ ធ្វើការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្ររង និងបរិញ្ញាបត្រ។ ក្នុងរយៈពេលបីខែ បន្ទាប់ពីថ្ងៃចាប់ដំណើរការបណ្តុះបណ្តាល សាកលវិទ្យាល័យនេះ ត្រូវរៀបចំកម្មវិធីសិក្សាលំអិតតាមកម្រិត និងមុខជំនាញ ដើម្បីសុំការឯកភាពពីក្រសួងអប់រំ យុវជន និងកីឡា។

**មាត្រា ៣ :** សាកលវិទ្យាល័យ ឡាយហ្វ មានប្រាំ មហាវិទ្យាល័យ :

- មហាវិទ្យាល័យ សិល្បៈ មនុស្សសាស្ត្រ និងភាសា
- មហាវិទ្យាល័យ គណិតសាស្ត្រ និងវិទ្យាសាស្ត្រ
- មហាវិទ្យាល័យ វិទ្យាសាស្ត្រសង្គម
- មហាវិទ្យាល័យ គ្រប់គ្រងពាណិជ្ជកម្ម
- មហាវិទ្យាល័យ គិលានុបដ្ឋាក និងឆ្មប ។

ទៅអនាគតសាកលវិទ្យាល័យនេះ អាចបើកសាខា មហាវិទ្យាល័យ មុខជំនាញ កម្រិត ឬថ្នាក់ និងប្រភេទបណ្តុះបណ្តាលដទៃទៀត ដោយរៀបចំសំណុំបែបបទសុំការអនុញ្ញាតពីក្រសួងអប់រំ យុវជន និងកីឡា ។

**មាត្រា ៤ :** សាកលវិទ្យាល័យ ឡាយហ្វ មានក្រុមប្រឹក្សាភិបាលមួយ ដើម្បីពិនិត្យ និងសម្រេច លើគោលនយោបាយ ផែនការអភិវឌ្ឍ កម្មវិធីសិក្សា និងការងារបច្ចេកទេសពាក់ព័ន្ធដទៃទៀត។ ការរៀបចំតួនាទី ភារកិច្ច រចនាសម្ព័ន្ធចាត់តាំងជាក់ស្តែង និងការតែងតាំងសាកលវិទ្យាធិការប្រតិបត្តិ ត្រូវកំណត់ដោយប្រធានក្រុមប្រឹក្សាភិបាល និងមានការទទួលស្គាល់ពីក្រសួងអប់រំ យុវជន និងកីឡា។

**មាត្រា ៥ :** សាកលវិទ្យាធិការប្រតិបត្តិ នៃសាកលវិទ្យាល័យ ឡាយហ្វ មានភារកិច្ចទទួលខុសត្រូវនៅចំពោះមុខច្បាប់ ក្នុងការគ្រប់គ្រងសាកលវិទ្យាល័យ ដោយធានាឱ្យបាននូវសុវត្ថិភាព និងសណ្តាប់ធ្នាប់សង្គម និងធ្វើរបាយការណ៍រាល់សកម្មភាពសិក្សា ជូនក្រសួងអប់រំ យុវជន និងកីឡា តាមការកំណត់ ។

**មាត្រា ៦ :** សាកលវិទ្យាល័យ ឡាយហ្វ ត្រូវគោរព និងអនុវត្តតាមការណែនាំ និងបទដ្ឋានដែលពាក់ព័ន្ធនឹងការងារបណ្តុះបណ្តាលរបស់ក្រសួងអប់រំ យុវជន និងកីឡា និងច្បាប់របស់រាជរដ្ឋាភិបាល សំដៅធានាគុណភាពអប់រំ។ ចំពោះការចូលរៀន នៅក្នុងមហាវិទ្យាល័យគិលានុបដ្ឋាក និងឆ្មប សាកលវិទ្យាល័យ ឡាយហ្វ ត្រូវគោរពតាមបទដ្ឋានរបស់ក្រសួងសុខាភិបាល និងក្រសួងអប់រំ យុវជន និងកីឡា ដែល

កំណត់ អំពីលក្ខខណ្ឌនៃការជ្រើសរើសនិស្សិតឱ្យចូលរៀន នៅតាមគ្រឹះស្ថានឧត្តមសិក្សា និងលក្ខខណ្ឌនៃការបណ្តុះបណ្តាល ក្នុងវិស័យសុខាភិបាល។

**មាត្រា ៧ :** និស្សិត ដែលបានរៀនចប់កម្មវិធីសិក្សា របស់សាកលវិទ្យាល័យឡាយហ្វ និងទទួលបានជោគជ័យ ក្នុងការប្រឡងបញ្ចប់ការសិក្សា ត្រូវទទួលសញ្ញាបត្រតាមកម្រិត និងឯកទេស ដែលបានសិក្សា។ សញ្ញាបត្រនេះ ផ្តល់ឱ្យដោយសាកលវិទ្យាល័យ ឡាយហ្វ ហើយត្រូវបានទទួលស្គាល់ ពីក្រសួងអប់រំ យុវជន និងកីឡា ក្នុងករណីដែលសាកលវិទ្យាល័យ ឡាយហ្វ បំពេញ និងអនុវត្តបានតាមគោលការណ៍ និងបទដ្ឋានកំណត់របស់ក្រសួងអប់រំ យុវជន និងកីឡា។

**មាត្រា ៨ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីក្រសួងសុខាភិបាល ស្ថាប័នពាក់ព័ន្ធ និងសាកលវិទ្យាល័យ ឡាយហ្វ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះ តទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ២០០៧

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- សាលាក្រុងព្រះសីហនុ
- ដូចមាត្រា ៨
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ